**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**
**អគ្គនាយកដ្ឋានយោធសេវា**
**នាយកដ្ឋានព័ត៌មាន**

លេខៈ ០១៥/ ឯ.៣ /២០១៦

# សេចក្តីប្រកាស ជូនដំណឹង

តបតាមការអញ្ជើញរបស់ ឯកឧត្តម រដ្ឋមន្ត្រីក្រសួងការពារប្រទេសសិង្ហបុរី គណៈប្រតិភូជាន់ខ្ពស់ក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយ ឯកឧត្តម នាយឧត្តមសេនីយ៍ **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នឹងអញ្ជើញ ទៅបំពេញទស្សនកិច្ចផ្លូវការ នៅប្រទេសសិង្ហបុរី នាវេលាម៉ោង ០៩:០០នាទី ព្រឹកថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០១៦ ។

ក្នុងអំឡុងពេលបំពេញទស្សនកិច្ចរយះពេល ៥ថ្ងៃ ចាប់ពីថ្ងៃទី១៥ ដល់ថ្ងៃទី១៩ ខែកុម្ភៈ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ទៀ បាញ់** អមដំណើរដោយ គណៈប្រតិភូជាន់ខ្ពស់ ក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា គ្រោងនឹងអញ្ជើញ ទៅចូលរួមការតាំងពិពណ៌ បច្ចេកវិទ្យា និង វិស្វកម្មលម្ហអាកាសសឹង្ហបុរី ក្នុងប្រទេសសឹង្ហបុរី ហើយគណៈប្រតិភូនឹងធ្វើមាតុភូមិនិវត្តន៍ មកកាន់ព្រះរាជាណាចក្រកម្ពុជាវិញ នៅវេលាម៉ោង ១៦.៣០នាទី នារសៀលថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ២០១៦ ៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៦

**នាយកដ្ឋានព័ត៌មាន**